ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១៧ ......សហវ.......

ថ្ងៃ សុក្រ ៤ រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២១

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល លេខ 118
ថ្ងៃ 10.09.21 9h30
បញ្ជូន

# សារាចរ
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត

អនុវត្តតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងដំណាក់កាលទី១ មាន ៣ជំហាន នៅរដ្ឋបាលកណ្តាលក្រសួង ស្ថាប័នចំនួន២៣ និងមន្ទីរ អង្គភាពជំនាញចំនួន១៨ នៅរាជធានី ខេត្ត កន្លងរួចមកហើយ។

នៅក្នុងដំណាក់កាលទី២ ជំហានទី១ នេះ ប្រព័ន្ធ NRMIS នឹងដាក់ឱ្យអនុវត្តដល់រដ្ឋបាលរាជធានី ខេត្ត សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ និងរដ្ឋបាលខេត្ត នៅទូទាំងប្រទេស ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តដាក់ឱ្យអនុវត្តប្រព័ន្ធ NRMIS ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត នៅក្នុងដំណាក់កាលនិងជំហានបន្តបន្ទាប់។

រដ្ឋបាលរាជធានី ខេត្ត ត្រូវប្រើប្រាស់លេខកូដបង់ចំណូលមិនមែនសារពើពន្ធដែលបានកំណត់ ដោយលម្អិតតាមចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត។ គ្រប់ចំណូលមិនមែនសារពើពន្ធទាំងអស់របស់រដ្ឋបាលរាជធានី ខេត្ត ដែលអាចប្រមូលនិងបង់ចូលថវិកាថ្នាក់ក្រោមជាតិ (ថវិការដ្ឋបាលរាជធានី ខេត្ត) បានលុះត្រាណាតែមានលេខកូដបង់ចំណូល ដែលអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិឬអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដែលស្នើដោយរដ្ឋបាលរាជធានី ខេត្តសាមី តាមរយៈអគ្គនាយដ្ឋានរដ្ឋបាលឬអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ។ បញ្ជីលេខកូដចំណូលមិនមែនសារពើពន្ធនៃរដ្ឋបាលរាជធានី ខេត្ត នីមួយៗ ជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ។

ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់វិក្កយបត្រដែលមានលេខកូដបង់ចំណូលមិនមែនសារពើពន្ធ ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត សម្រាប់រដ្ឋបាលរាជធានី ខេត្ត នៅទូទាំងប្រទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចដាក់ចេញនូវសេចក្តីណែនាំអំពីនីតិវិធីនៃការប្រមូលនិងការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS និងបង់ចំណូលទៅ ធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ដូចខាងក្រោម÷

១. ការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS ÷ រដ្ឋបាលរាជធានី ខេត្ត ក្រោយពីទទួលបានចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ត្រូវកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

២. ពេលបង់ចំណូលទៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ÷

-ចំពោះចំណូលពីសេវាសាធារណៈ រដ្ឋបាលរាជធានី ខេត្ត ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ចំនួន ០២ច្បាប់ ដោយ ០១ច្បាប់រក្សាទុកជូនធនាគារជាតិនៃកម្ពុជា, ធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ និង ០១ច្បាប់ទៀត រក្សាទុកដោយរជ្ជទេយ្យករចំណូលរបស់រដ្ឋបាលរាជធានី ខេត្តសាមី ដើម្បីភ្ជាប់ជាមួយសាច់ប្រាក់ដែលត្រូវបង់ ឬ បង្វែរចូល គណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ

-ចំពោះចំណូលពីទ្រព្យសម្បត្តិរដ្ឋ រដ្ឋបាលរាជធានី ខេត្ត ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជនដើម្បីបង់ប្រាក់នៅធនាគារជាតិនៃកម្ពុជា, ធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ

-ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត រដ្ឋបាលរាជធានី ខេត្ត អាចអនុវត្តតាមនីតិវិធីនៃការបង់ចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋតាមយថាប្រភេទនៃចំណូលជាក់ស្តែង។

-ក្រោយពីបានបង់ប្រាក់ចូល គណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ រដ្ឋបាលរាជធានី ខេត្ត ត្រូវកត់ត្រាលេខយោងលើបណ្ណបង់ប្រាក់ (Bank Slip) ឬ ប្រកាសឥណពន្ធ (Debit Advice) ឬ បណ្ណផ្ទេរប្រាក់/ ឥណទាន (Remittance Slip) ចូលក្នុងប្រព័ន្ធ NRMIS ដើម្បីបញ្ចប់ប្រតិបត្តិការ នៃវិក្កយបត្រ (ក្នុងករណីជាប្រាក់ដុល្លារត្រូវបញ្ចូលអត្រាប្តូរប្រាក់តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា)។

-ចំពោះចំណូលប្រមូលបាននៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ហើយកត់ត្រាជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

- រជ្ជទេយ្យករចំណូលរបស់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត គឺជាអ្នកកត់ត្រាបង្កើតប្រតិបត្តិការ និងវិក្កយបត្រក្នុងប្រព័ន្ធ NRMIS ហើយយកសាច់ប្រាក់បង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ ឬនៅគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ បន្ទាប់មកត្រូវផ្តល់បណ្ណបង់ប្រាក់ដែលខ្លួនបានបង់នោះ ជូនទៅរជ្ជទេយ្យករចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត

- រជ្ជទេយ្យករចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត ជាអ្នកបញ្ចប់វិក្កយបត្រ និងបោះពុម្ពសលាកបត្របង់ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ពីប្រព័ន្ធ NRMIS។

៣. ការបង្វែរចំណូលទៅថវិកា ÷

- ប្រព័ន្ធ NRMIS នឹងធ្វើការបង្កើតសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដោយស្វ័យប្រវត្តិបន្ទាប់ពីការធ្វើប្រតិបត្តិការបញ្ចប់វិក្កយបត្រ ដើម្បីបោះពុម្ពសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ចេញពីប្រព័ន្ធ NRMIS។

-រជ្ជទេយ្យករចំណូល ឬ មន្ត្រីទទួលបន្ទុកប្រមូលចំណូល របស់រដ្ឋបាលរាជធានី ខេត្ត នីមួយៗត្រូវពិនិត្យសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត រួចបញ្ជូនមក រតនាគាររាជធានី ខេត្ត ជាមុនតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម Telegram បន្ទាប់មក ត្រូវបញ្ជូនសលាកបត្របង់ចំណូលថវិកា ដែលមានការចុះហត្ថលេខា (ច្បាប់ដើម) មករតនាគាររាជធានី ខេត្តតាមក្រោយ។

- ចំពោះមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដែលធ្លាប់បានអនុវត្តការរៀបចំសលាកបត្របង់ចំណូលថវិកាថ្នាក់ក្រោមជាតិជួសមុខឱ្យរដ្ឋបាលរាជធានី ខេត្ត នូវចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតមានជាអាទិ៍÷ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសម្បទានសេវាសាធារណៈ និងចំណូលពីការលក់ទ្រព្យសម្បត្តិខូចខាត ឬចាស់ទ្រុឌទ្រោមជាដើម ត្រូវធ្វើការផ្ទេរការងាររៀបចំសលាកបត្របង់ចំណូលថវិកាទាំងនោះមកឱ្យរដ្ឋបាលរាជធានី ខេត្ត ជាអ្នករៀបចំដោយផ្ទាល់វិញ។

៤.ការទូទាត់ប្រាក់រង្វាន់÷ ដើម្បីរៀបចំការទូទាត់ប្រាក់រង្វាន់ដែលរដ្ឋបាលរាជធានី ខេត្ត ដែលបានដកកន្លងមក រដ្ឋបាលរាជធានី ខេត្ត ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដើម្បីកត់ត្រា ដោយត្រូវជ្រើសរើសយក សលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលបានបង្វែរចូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត តាមរយៈសាច់ប្រាក់ដែលបានបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ។ បន្ទាប់មកត្រូវបោះពុម្ពលិខិតស្នើសុំផ្សេងៗ និងរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងបណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក និងផ្ញើមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីអនុវត្តនីតិវិធីបន្ត។ សម្រាប់ប្រតិបត្តិចំណាយត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ បន្ទាប់ពីទទួលបានសារាចរនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល និងធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់រដ្ឋបាលរាជធានី ខេត្ត សាមីឱ្យប្រើប្រាស់វិក្កយបត្រដែលមានលេខកូដបង់ចំណូលជាកំហិត។

ទទួលបានសារាចរនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល÷</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ